# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២៦៤៩ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.០៧....ខែ.ឧសភា.ឆ្នាំ ២០១៥

**សូមគោរពជូន**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

**-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃព្រឹទ្ធសភា**

**-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃរដ្ឋសភា**

**-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**-ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង**

**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា**

**-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា**

**-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**

**-ឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់**

**កម្មវត្ថុ ៖** របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែមេសា ឆ្នាំ២០១៥** និងទិសដៅអនុវត្តបន្ត ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមផ្ញើជូនឯកឧត្តម នូវរបាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែមេសា ឆ្នាំ២០១៥** ចំនួន០១ច្បាប់ ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អ៊ុក រ៉ាប៊ុន**

**ចម្លងជូន**

-គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង

-ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែមេសា ឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអង្គភាពជំនាញនិងមន្ទីរកសិកម្មរាជធានី ខេត្ត ជាសេនាធិការ បានខិតខំបំពេញភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវដោយតម្រង់ទិសដៅតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ដ៏ត្រចះត្រចង់របស់រាជរដ្ឋាភិបាលយ៉ាងយកចិត្តទុកដាក់។ នៅដើមខែមេសា ឆ្នាំ២០១៥កន្លងមកនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៤-២០១៥ និងលើកទិសដៅឆ្នាំ២០១៥-២០១៦ ដែលពិធីបិទសន្និបាតបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ មកទល់ពេលនេះ កសិករទូទាំងប្រទេសបានបញ្ចប់ការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៤-២០១៥ លើផ្ទៃដីចំនួន៤៩០.៩៣៥ហិកតា ស្មើនឹង១១៨,០២% នៃផែនការ៤១៥.៩៦៥ហិកតា លើសឆ្នាំមុន៦.២៣៨ហិកតា ក្នុងនោះខេត្តមួយចំនួនបានបញ្ចប់ការដាំដុះលើសផែនការ លើកលែងតែខេត្តកំពង់ស្ពឺ កំពត ព្រះវិហារ ឧត្តរមានជ័យ និងខេត្តប៉ៃលិន ដែលអនុវត្តមិនបានគ្រប់ផែនការ ដោយសារខ្វះប្រភពទឹកស្រោចស្រព។ ក្រៅពីដំណាំស្រូវប្រជាកសិករកំពុងមមាញឹកផងដែរលើការដាំដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មផ្សេងៗទៀត។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែមេសា ឆ្នាំ២០១៥នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលបញ្ចប់ការប្រមូលផលដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៤-២០១៥

ការងារប្រមូលផលស្រូវប្រាំងលើផ្ទៃដីអនុវត្តបានចំនួន៤៩០.៨៦០ហិកតា ស្មើ៩៩,៩៨ភាគរយ នៃផ្ទៃដីអនុវត្តដោយទទួលបានបរិមាណផលសរុបចំនួន២.១៨០.៨៩៥តោន និងទិន្នផលជាមធ្យមចំនួន៤,៤៤៣តោនក្នុងមួយហិកតា (ឆ្នាំមុន៤,៣៧២តោនក្នុងមួយហិកតា) ក្នុងនោះ៖

- ផ្ទៃដីភ្ជួររាស់សរុបចំនួន៥៨២.៣៨០ហិកតា លើសឆ្នាំមុនចំនួន៣៣.៧៧១ហិកតា
- ផ្ទៃដីសាបសរុបចំនួន៤.០៣៤ហិកតា តិចជាងឆ្នាំមុនចំនួន៨២៨ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៤៩០.៩៣៥ហិកតា ស្មើនឹង១១៨,០២ភាគរយនៃផែនការ៤១៥.៩៦៥ ហិកតា លើសឆ្នាំមុនចំនួន៦.២៣៨ហិកតា។

#### ១.២ ដំណាំរួមផ្សំ :

- ផ្ទៃដីសម្រេចបានចំនួន៨៤.៧១៧ហិកតា លើសឆ្នាំមុនចំនួន៨០២ហិកតា
- ដំណាំឧស្សាហកម្ម : ផ្ទៃដីសម្រេចបាន២១.៣០៤ហិកតា លើសឆ្នាំមុនចំនួន១.៩៣៨ហិកតា។


អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ១៨៧,៤៧ | ១១១,៤៦ |
| | **សរុប I** | **៤០៦,៦០** | **៣៤៤,៣១** | **១៨៧,៤៧** | **១១១,៤៦** |
| II-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១០.៧១៩,២៧ | ៥.៣២៧,០៥ | ៦.៣២៨,៥៦ | ៤.០៨០,២០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វាំប់ប៊ើលីមីធីត (រតនគីរី) | ៧៨,៥៣ | ២.០៦៤,៣០ | ១០៤,០៨ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ១.០៨២,១២ | ៣០៤,១៩ | ២០០,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៥៧១,៥២ | ៣.១៣៩,៨៣ | ១.៨២៦,២០ | ១.៤៧៥,២០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ១.៣៨៥,៣៥ | ៨២៤,៤០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វរីសស៍ (ស្នួល) | ១.៧៤៤,៧៨ | ២.៦៤១,៤៣ | ៦៧៦,៤៨ | ៤៦០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ៦២៦,៦៥ | ២០៤,៦០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.១១១,៦៥ | ១.២១៥,៥៥ | ៦២១,៦៣ | ៣៥៥,៤០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ៨៧៥,៦៦ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.៣៣៧,៩២ | ១.៨៦៤,៩៥ | ១.៣៦០,០០ |
| | **សរុប II** | **២៨.១៥៩,៥៤** | **២៥.២៦៨,១៤** | **១៣.៧៣៨,០៩** | **៨.៩៥៩,៨០** |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៧០៨,០០ | ១៤១.២០៤,០០ | ៦៤១,៨១ | ៦៤១,៨១ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,០០ | ៧៩.០៧៥,០០ | ២០.២០០,០០ | ១៨.៨០០,០០ |
| | **សរុប III** | **៦១.៩៧៩,០០** | **២២០.២៧៩,០០** | **២០.៨៤១,៨១** | **១៩.៤៤១,៨១** |
| | **សរុប I+II+III** | **៩០.៥៤៥,១៤** | **២៤៥.៨៩១,៤៥** | **៣៤.៧៦៧,៣៧** | **២៨.៥១៣,០៧** |

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- រៀបចំធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកលើកទី៤១ ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍ក្នុងស្រុក សម្រាប់ការទទួលស្គាល់ជាផ្លូវការពីវិទ្យាស្ថាន
- លាបថ្នាំរំញោចអេតេហ្វូនគ្រប់ចម្ការពិសោធន៍ទាំងក្នុងនិងក្រៅស្ថានីយ៍
- វិភាគសរីរៈទឹកជ័រលើចម្ការពិសោធន៍ក្លូន PB260, PB330 និង IRCA209
- ស្រង់និងត្រួតពិនិត្យទិន្នន័យទឹកជ័រចម្ការពិសោធន៍ និងបញ្ចូលទិន្នន័យចម្ការពិសោធន៍
- បើកវគ្គបណ្តុះបណ្តាលស្តីពី"ការបង្កើតនិងគ្រប់គ្រងច្បារពូជ"
- ដឹកនាំការសរសេរសារណារបស់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាកលវិទ្យាល័យស្វាយរៀង។

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យាបាល

### ៣.១ ការងារវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ

- ជ្រូកសរុបចំនួន២៣៥ក្បាល នៅក្នុងស្ថានីយពិសោធន៍ពូជជ្រូក ក្នុងនោះជ្រូកបាចំនួន៩ក្បាល ជ្រូកមេចំនួន៩២ក្បាល និងកូនជ្រូកចំនួន១៣៤ក្បាល
- គោសរុបចំនួន១៥៩ក្បាល នៅក្នុងស្ថានីយចិញ្ចឹមគោ ក្នុងនោះគោញីចំនួន១១១ក្បាល និងគោឈ្មោលចំនួន៤៨ក្បាល

- វិទ្យាស្ថានបានខិតខំពង្រឹងសកម្មភាពពិសោធន៍ស្រាវជ្រាវដូចខាងក្រោម៖

+ កែច្នៃទឹកមេជីវិតនៅវិទ្យាស្ថានពិសោធន៍ពូជគោនៅភ្នំតាម៉ៅ

+ រៀបចំសកម្មភាពគម្រោងគាំទ្រដោយសហភាពអឺរ៉ុបទាក់ទងនឹងការងារកែច្នៃទឹកមេជីវិតគោ

+ លើកសំណើទៅភាគីចិនដើម្បីបង្កើតមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតគោ មន្ទីរពិសោធន៍វិភាគចំណីសត្វ មន្ទីរពិសោធន៍សេនេទិច និងមន្ទីរពិសោធន៍កាកសំណល់ថ្នាំ

+ រៀបចំស្នើសុំទិញឧបករណ៍វិភាគចំណីតាមរយៈគម្រោងសហភាពអឺរ៉ុបនិងគម្រោង SPS។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

- ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី ជំងឺសារទឹកចំនួន៤៤.៦៥២ក្បាល និងជំងឺអុតក្តាមចំនួន៤៤៣ក្បាល។

- ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៣.៧៤០ក្បាល ជំងឺប៉េស្តចំនួន៩.៦៩២ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៥.៧៦៨ក្បាល ជំងឺអុតក្តាមចំនួន១៧៨ក្បាល ជំងឺអូហ្សេស្គីចំនួន១.៣៩៨ក្បាល ជំងឺកញ្ជ្រឹលចំនួន១៧០ក្បាល និងជំងឺជាតិដែកចំនួន១៨៧ក្បាល

- ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន២៧.១៥៧ក្បាល ជំងឺញីវកាសចំនួន៥០.១៨៦ក្បាល ជំងឺអាសន្នរោគចំនួន២០.៣៨៥ក្បាល និងជំងឺប៉េស្តទាចំនួន១២.៨៨០ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ

- ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

- រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

- អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅតាមខេត្ត-រាជធានី

- បានពិនិត្យវត្ថុវិភាគសរុបចំនួន៨៦សំណាក និងផ្នែកសរីរាគសាស្រ្តសរុបចំនួន៧ក្បាល

- ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន២៤១ឡ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

- ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមជ្រូកចំនួន៤៧លើក មាន់ចំនួន៣៦លើក ទាចំនួន១៣លើក កន្លែងពិឃាតមាន់ចំនួន១៨លើក កន្លែងលក់មាន់ចំនួន១៨លើក ទ្រុងចិញ្ចឹមចំនួន២០៤លើក និងបរិវេណភូមិចំនួន១៩លើក។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

- ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង កំពង់ធំ និងសៀមរាប) ដែលមានសត្វស្លាបប្រមាណ១៨០ប្រភេទ (ប្រហែល១០១.៤១៨ក្បាល)

- រៀបចំអាហារដ្ឋានត្មាតនៅព្រៃការពារព្រះវិហារ ស្ទឹងត្រែង និងក្រចេះ ដោយរាប់ឃើញសត្វត្មាតសរុបចំនួនប្រមាណ៤៩ក្បាល

- ការពារសម្បុកសត្វត្រដក់តូចចំនួន២ សត្វត្រយ៉ងចង្កំ ក ស ចំនួន១៨សម្បុក ត្មាតចំនួន៣ និងរំពេទន្លេចំនួន៤នៅខេត្តស្ទឹងត្រែង ក្រចេះ និងព្រះវិហារ។

### ៤.២ ការងារសហគមន៍ព្រៃឈើ

- ធ្វើការអប់រំផ្សព្វផ្សាយពីសារសំខាន់នៃការអភិរក្សសត្វព្រៃ ពង្រឹងការអនុវត្តច្បាប់ ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់គណៈកម្មាធិការសហគមន៍ ក្រុមសន្សំប្រាក់ ការចិញ្ចឹមមាន់ ការអភិវឌ្ឍកសិកម្មជាលក្ខណៈគ្រួសារ ស្រូវសង្គ្រោះសត្វព្រៃ ការអភិរក្សសត្វក្តាន់តាមដងទន្លេមេគង្គ និងការគ្រប់គ្រងកម្មវិធីទេសចរណ៍ធម្មជាតិ ដោយមានអ្នកចូលរួមសរុបចំនួន៥៩៥នាក់ (ស្ត្រីចំនួន២៨៤នាក់)

- សហការជាមួយអង្គការ **Wildlife Alliance** អនុវត្តគម្រោងស្តារលទ្ធភាពជីវសាស្រ្តសត្វព្រៃនៅជីផាត ខេត្តកោះកុង និងកម្មវិធីស្តារលទ្ធភាពជីវសាស្រ្តសត្វព្រៃនៅឧទ្យានអង្គរ ខេត្តសៀមរាប សកម្មភាពស្តារលទ្ធភាពផ្តល់ចំណីនិងថែទាំរាល់ថ្ងៃសត្វក្នុងទ្រុងដែលបានដោះលែងមាន៖ ខ្លាឃ្មុំតូច២ក្បាល (ញី-ឈ្មោល) សំពោចក្រអូប៥ក្បាល ស្វាក្តាម២ក្បាល(ញី-ឈ្មោល) សេកសោម៤ក្បាល សេកអាត់៣ក្បាល កេងកងធំ១ក្បាល ពង្រូល១គូ និងឆ្មាដាវ១ក្បាល ទោច

ចម្កុដ១គូ ស្វាព្រាមពាក្បាល(ញី២-ឈ្មោល១)។ បានបង្ការភ្លើងព្រៃជុំវិញស្នាក់ការដោយដុតស្មៅជាឡូត៍តូចៗចូលរួមធ្វើផែនការ និងឧបត្ថម្ភជាសម្ភារដល់ក្រុមល្បាតសហគមន៍អេកូទេសចរណ៍ជីផាត និងចុះសិក្សាទីតាំងសម្រាប់សាងសង់ទ្រុងឈ្លូស ប្រើស ក្នុងបរិវេណព្រៃអង្គរធំ

- ចុះប្រមូលទិន្នន័យប្រើប្រាស់ដីធ្លីសម្រាប់សាងសង់លំនៅដ្ឋានចំនួន៧២គ្រួសារ របស់ប្រជាពលរដ្ឋនៅភូមិណារ៉ុងស្ថិតនៅក្នុងដែនព្រៃការពារព្រះវិហារ និងវាស់វែងដីស្រែចំនួន៥៣កន្លែងរបស់សមាជិកសហគមន៍ នៅភូមិគុណភាព និងភូមិណារ៉ុង

- មានភ្ញៀវទេសចរចំនួន៧៩នាក់មកទស្សនាតំបន់អភិរក្សជីវចម្រុះវីនសៃ-សៀមប៉ាង កំពង់ធំ-សៀមរាប តំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្មនិងព្រៃការពារព្រះវិហារដោយសហគមន៍មូលដ្ឋានទទួលប្រាក់ចំណូលចំនួន៥៦៤ដុល្លារ

- បន្តសហការជាមួយអង្គការ CSIRO នៃប្រទេសអូស្ត្រាលី បង្កើតចម្ការពូជឈើ អាកាស្យាម៉ង់ស្យូមទំហំ០២ហិកតា នៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើក្បាលឆាយ

- បន្តការចុះស្រាវជ្រាវអំពីសត្វល្អិត Leptocybe invasa នៅក្នុងស្ថានីយដាំឈើចំនួន៣ទីតាំង (មានក ស្ទួលទ្រេតក្រសាំង) និងក្រុមហ៊ុន Kamarkara។ ជាលទ្ធផលនៃការស្រាវជ្រាវបានរកឃើញនិងប្រមូលសំណាកនៃសត្វល្អិតនៅក្នុងចម្ការឈើប្រេងខ្យល់ (Eucalyptus K7) ខេត្តបន្ទាយមានជ័យ ហើយក្រុមការងារនឹងបន្តចុះស្រាវជ្រាវលើកទី២ នៅតំបន់ផ្សេងៗទៀត។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្នុងខែមេសា ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សាៈ សត្វចំណូលថ្មីចំនួន៧០ក្បាល សត្វកើតថ្មីចំនួន២៣ក្បាល សត្វដោះលែងចំនួន១៦៥ក្បាល សត្វស្លាប់ចំនួន៩ក្បាល ព្យាបាលសត្វចំនួន៤០២ក្បាល យកសំណាកទៅពិសោធន៍ចំនួន១០៩ក្បាល ធ្វើឲ្យសន្លប់ចំនួន៤ក្បាល ទម្លាក់សត្វល្អិតចំនួន៣ក្បាល វះកាត់សាកសពសត្វចំនួន១១ក្បាល ឆ្ការអនាម័យព្រៃចំនួន៧.៦៩០ម$^{២}$ ដាំកូនឈើចំនួន២២ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៥០៩នាក់

- ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្តាមមេ-បាពូជ និងកូនស្វាក្តាមចំនួន៤៤.៣០៨ក្បាល។

### ៤.៤ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

- តាមដានបំលាស់ទីរបស់ក្រពើដែលបានដោះលែងកាលពីឆ្នាំ២០១២-២០១៤ ដោយឧបករណ៍វិទ្យុសំឡេង (Radio Tracking) រកឃើញក្រពើចំនួន០១ក្បាល។

### ៤.៥ ការងារដាំដើមឈើ

- ក្នុងខែមេសា ឆ្នាំ២០១៥នេះ ការងារដាំឈើទូទាំងប្រទេសសម្រេចឈូសឆាយដីព្រៃបានទំហំចំនួន១.២៦០ហិកតា

- ក្រុមហ៊ុន ស៊ីងបាយអូចេក(ខេមបូឌា) ខូអិលធីឌី បានកាប់ឆ្ការនិងឈូសឆាយសម្អាតដីទំហំ៥០០ហិកតា និងផលិតពូជកូនឈើចំនួន៤០០.០០០ដើម

- ក្រុមហ៊ុន អូជី (ខេមបូឌា) ផ្លេនថេសិន ហ្វរីស ឌមភេនី លីមីធីត បានរៀបចំដាំពិសោធន៍ពូជលើទំហំដី ៥ហិកតា

- ការដាំឈើជាចម្ការថ្មីរបស់រដ្ឋបាលព្រៃឈើនៅតាមបណ្តាស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន៣ទីតាំង ដោយបណ្តុះកូនឈើបានចំនួន២០០.០០០ដើម ឈូសឆាយដីព្រៃបានចំនួន១២០ហិកតា និងថែទាំដាំជួសចម្ការឈើចាស់នៅស្ថានីយដាំឈើចំនួន១០ មានផ្ទៃដីទំហំចំនួន២.៨១៨ហិកតា ត្រូវបានធ្វើការថែទាំ និងការពារជាប្រចាំ ជាពិសេសគឺការកាប់រានដីនិងភ្លើងព្រៃ

- ជ្រើសរើសទីតាំងរុក្ខទិវាថ្នាក់ជាតិសម្រាប់ពិធីបុណ្យរុក្ខទិវា៩ កក្កដា ២០១៥ នៅតំបន់ថ្មសំលៀងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដោយឈូសឆាយដីបានចំនួន១០ហិកតា និងត្រៀមពូជកូនឈើសម្រាប់ដាំចំនួន១២.០០០ដើម

- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានឈូសឆាយដីទំហំសរុប៦០០ហិកតា

- រៀបចំស្ទួនអាពាហ៍ពិពាហ៍ចំនួន៣៣កន្លែងនៅក្នុងខណ្ឌរដ្ឋបាលព្រៃឈើចំនួន១៨ លើផ្ទៃដីទំហំ៤១៣ហិកតា

- កំពុងថែទាំឡូត៍ស្រាវជ្រាវ កសិ-រុក្ខកម្មទំហំ ០៥ហិកតា ដែលមានទីតាំងនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ។

### ៤.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើលើសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ថាច់ វ៉ុង ខេមបូឌា ខុអិលធីឌី នៅខេត្តមណ្ឌលគិរី

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើអារ ឈើឡាំង(Chanfuta)ជូនក្រុមហ៊ុនចំនួន១ ដែលមានបរិមាណឈើចំនួន៨០០ម៣ និងគោលការណ៍នាំចេញឈើចន្ទន៍ក្រស្នាជូនក្រុមហ៊ុនចំនួន១ ដែលមានបរិមាណចំនួន៥០០គ.ក្រ និងប្រេងកែច្នៃចំនួន១៦៦លីត្រ។

### ៤.៧ ការងារចំណូលព្រៃឈើ

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជនៈ ឈើហ៊ុបមូលសរុបចំនួន ៨.០៤៩ម៣ កូនឈើចំនួន២១០.៩៣៣ដើម អុសចម្រុះចំនួន៤២.៥៩៤ស្ទែរ ជ័រទឹកចំនួន១៦០តោន ធ្យូងចំនួន៣០តោន និងឬស្សីព្រៃចំនួន៦២៧តោន

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញជូនក្រុមហ៊ុនចំនួន២ ស្មើនឹង៣០សន្លឹក ដែលមានបរិមាណឈើកែច្នៃចំនួន៣.៧៤៧ម៣

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចូលជូនក្រុមហ៊ុនចំនួន១ ស្មើនឹង៣សន្លឹក ដែលមានបរិមាណឈើចំនួន១១៩ម៣

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន១.០០១.៩២៦.៩៤៩រៀល និងចំណូលពីសេវាសាធារណៈចំនួន៦៩៤.៥៤៣.២៨៦រៀល និង៦.២៦២,២៥ដុល្លារ។

### ៤.៨ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែមេសា ឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៧៧ករណី ដោយបញ្ជូនទៅតុលាការចំនួន១៤២ករណី និងពិន័យអន្តរការណ៍ចំនួន៣៥ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៣៨ម៣ ឈើអារចំនួន៣៩២ម៣ ឈើប្រាក់គ្រញូងចំនួន៣១ម៣និង១៤៥គ.ក្រ សត្វព្រៃចម្រុះប្រភេទចំនួន១៥១គ.ក្រនិង៩៥ក្បាល និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន៣០៨ហិកតាត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការ និងដកហូតរណារយន្តចំនួន០១គ្រឿង

- បាននឹងដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃដែលបានទទួលទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឲ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ធ្វើការឆ្លើយតបរហ័សលើព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលមានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន ១០២ករណី។ ការចុះផ្សាយនេះបានឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និងអវិជ្ជមានផងដែរ ហើយអត្ថបទសារព័ត៌មានដែលចុះផ្សាយចំនួន២៣ករណីត្រូវបានជ្រើសរើសរួចបញ្ជូនទៅបណ្តាខណ្ឌរដ្ឋបាលព្រៃឈើដើម្បីបំភ្លឺ។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៤-២០១៥ សរុបបានចំនួន១២.២៨៥តោន ស្មើ១០២,៣៨% នៃផែនការ ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៦.៧១៥តោន

- នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៥ ក្នុងខែចំនួន៣០.០០០តោន សរុបបានចំនួន១១៥.២៥០តោន ស្មើ៣២,៩៣% នៃផែនការ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២៤.៧៥០តោន

- នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៥ ក្នុងខែចំនួន៥.០០០តោន សរុបបានចំនួន២៨.១៥៥តោន ស្មើ១៨,៧៧% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១១.៨៤៥តោន(មូលហេតុនៃការថយចុះគឺបណ្តាលមកពីការប្រែប្រួលអាកាសធាតុ)។

៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៥

- ក្នុងខែចំនួន៩.៥០០តោន សរុបចំនួន៣១.៧៣៥តោន ស្មើ២៨,៨៥% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣.៧៦៥តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែចំនួន៩.៥២០តោន សរុបបានចំនួន៣៥.០៥០តោន ស្មើ២៤,៣៤% នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០៥០តោន

- ការចិញ្ចឹមក្រពើ ក្នុងខែចំនួន៩.០០០ក្បាល សរុបបានចំនួន៣៤.០០០ក្បាល ស្មើ១៣,៦០% នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១១.០០០ក្បាល

- ការភ្ញាស់កូនត្រីពូជ ក្នុងខែចំនួនប្រមាណ៥.០០០.០០០កូន សរុបបានចំនួនប្រមាណ៣២.០០០.០០០កូន ស្មើ១៧,៧៨% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួនប្រមាណ២.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៤-២០១៥ ក្នុងខែចំនួន៤.០០០តោន សរុបបានចំនួន២១.៥០០តោន ស្មើ២៦,២២% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣.៥០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ ក្នុងខែចំនួន៩០០តោន សរុបបានចំនួន៣.២០០តោន ស្មើ៤០% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣០០តោន

- ការផលិតទឹកត្រី ក្នុងខែចំនួន៨.០០០.០០០លីត្រ សរុបបានចំនួន២២.០០០.០០០លីត្រ ស្មើ៤៤% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ ក្នុងខែចំនួន៩៥០តោន សរុបបានចំនួន៣.៨០០តោន ស្មើ២៥,៣៣% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០០តោន

- ផលនេសាទកែច្នៃ ក្នុងខែចំនួន៦០០តោន សរុបបានចំនួន២.២៥០តោន ស្មើ៤៥% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១៥០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- កំណត់ហេតុបទល្មើស សរុបចំនួន២៨៥ករណី ដែលកើតមាននៅតំបន់ទឹកសាប២៦០ករណី និងតំបន់សមុទ្រ២៥ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៧០២ករណី គឺតំបន់ទឹកសាបថយចុះ៦៩៦ករណីនិងតំបន់សមុទ្រថយចុះ៦ករណី។ សមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល ក្នុងខែចំនួន៣៩០.៣០០.០០០រៀល សរុបបានចំនួន១.៣៣៧.៥៦៨.៥០០រៀល ស្មើ៤៤,៥៩% នៃផែនការ៣.០០០.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៣០.៤៥១.៧៥០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះជ្រើសរើសទីកន្លែងត្រួតពិនិត្យ និងចែកសម្ភារពិសោធន៍ដល់អ្នកសហការ

- ចុះប្រមូលពូជស្រូវប្រពៃណីនិងដំណាំផ្សេងៗ និងសិក្សាស្រាវជ្រាវស្តីពីការប្រើប្រាស់ជីលើដំណាំដំឡូងមីរបស់កសិករ ព្រមទាំងប្រមូលព័ត៌មានស្តីពីខ្សែចង្វាក់ផលិតកម្មដំណាំស្វាយ និងប្រមូលទិន្នន័យស្តីពីអាកាសធាតុនិងសំណាកទឹកក្រោមដី។

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៤៧៧ច្បាប់ សរុបចំនួន១.៨៣៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទក្នុងខែចំនួន២៤៩ច្បាប់ សរុបចំនួន១.២៤១ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១០៣ច្បាប់ សរុបចំនួន៤២២ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៦៦៤ច្បាប់ សរុបចំនួន២.៥៦៩ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៣៦ច្បាប់ សរុបចំនួន២១៤ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន២៧ច្បាប់ សរុបចំនួន១១២ច្បាប់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៧៨៧នាក់ នារីចំនួន១.៣៥៨នាក់ ស្មើនឹង២០% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន៤.១៣០នាក់ ក្នុងនោះនារីចំនួន៧៨២នាក់ ស្មើនឹង១៩%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៥៧នាក់ ក្នុងនោះនារីចំនួន៥៧៦នាក់ ស្មើនឹង២២%
- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន០៩នាក់ ក្នុងនោះបោះបង់ការងារចំនួន០១នាក់ សុំលាឈប់ពីការងារចំនួន០៤នាក់ និងមរណភាពចំនួន០៤នាក់
- ចេញច្បាប់សម្រាកប្រចាំឆ្នាំចំនួន០៥នាក់ ច្បាប់ព្យាបាលជំងឺចំនួន០៥នាក់ និងច្បាប់សម្រាកមាតុភាពចំនួន០៤នាក់
- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន០១នាក់ ផ្ទេរចូលក្រសួងចំនួន០១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៦នាក់
- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន១៩នាក់ និងចូលធ្វើការងារវិញចំនួន០៧នាក់
- ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន០៨នាក់ និងក្នុងប្រទេសចំនួន០១នាក់
- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- មន្ត្រីចំនួន២៥រូប ចូលរួមនិងសហការរៀបចំកិច្ចប្រជុំលើកទី៦របស់ក្រុមការងារជំនាញស្តីពីការអនុវត្តកសិកម្មល្អ នៅខេត្តសៀមរាប
- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៣០នាក់ នៅក្នុងប្រទេសចំនួន៨
- រៀបចំគម្រោងអាទិភាពចំនួន៣ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិន បញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានទឹកប្រាក់សរុប៨.០៥០.០០០ដុល្លារអាមេរិក ក្នុងចំណោម១០គម្រោងអាទិភាពដែលបានជ្រើសរើសដោយក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន។

## ១០ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបចំនួន១.២២៣នាក់(ស្រី៣៩៦នាក់) ក្នុងនោះនិស្សិតបរិញ្ញាចំនួន១.០១៥នាក់(ស្រី៣៥០នាក់) និងនិស្សិតបរិញ្ញារងចំនួន២០៨នាក់(ស្រី៤៦នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ សហការជាមួយក្រសួងអប់រំយុវជននិងកីឡាក្នុងការកែលម្អកម្មវិធីសិក្សាក្នុងគោលបំណង ប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀបទៅជាសាកលវិទ្យាល័យជាតិព្រែកលៀប។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបមានចំនួន១.២១៨នាក់(ស្រី៤៥៨នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប៨៤៨នាក់ (ស្រី៣៨១នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៦៩០នាក់ (ស្រី២៨១នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម១៥៨នាក់(ស្រី១០០នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- និស្សិតសិក្សាបង់ថ្លៃ២២៨នាក់ (ស្រី៦៧នាក់) ថ្នាក់បរិញ្ញាចំនួន២១៧នាក់(ស្រី៦៦នាក់) និងថ្នាក់បរិញ្ញារងចំនួន១១នាក់ (ស្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។ សាលាជាតិបានលើកគម្រោងចំនួន១១គម្រោងស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់(ស្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមបានបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានរៀបចំធ្វើសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធស្តីពីការអភិវឌ្ឍកម្មវិធីសិក្សារបស់មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ និងកសិឧស្សាហកម្មក្រោមជំនួយរបស់គម្រោងSPS និងបានធ្វើសិក្ខាសាលាជូននិស្សិតស្តីពីឱកាសទទួលអាហារូបករណ៍ពីសាកលវិទ្យាល័យ Purdue University សហរដ្ឋអាមេរិក និងឱកាសទទួលអាហារូបករណ៍ពីគម្រោង Lotus+ ទៅសិក្សានៅសាកលវិទ្យាល័យនៃសហភាពអឺរ៉ុប។ បញ្ជូនសាស្ត្រាចារ្យចូលរួមប្រជុំការងារសហប្រតិបត្តិការបច្ចេកទេសចំនួន០៤រូប នៅប្រទេសថៃ ឥណ្ឌូនេស៊ី និងនៅប្រទេសជប៉ុន។ ក្នុងកម្មវិធីផ្លាស់ប្តូរនិស្សិត សាកលវិទ្យាល័យបានទទួលនិស្សិតចំនួន៣៥នាក់ ពីសាកលវិទ្យាល័យ Duksoung Women University ប្រទេសកូរ៉េ និងបានបញ្ជូននិស្សិត២នាក់ ទៅចូលរួមកម្មវិធីបោះជំរុំនៅប្រទេសថៃ លើប្រធានបទ "សេដ្ឋកិច្ចអាស៊ាន" ផងដែរ ។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឲ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឲ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិ-ពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឲ្យកាន់តែទូលំទូលាយ។

## III- ទិសដៅអនុវត្តបន្ត

### ១.ផ្នែកដាំដុះ :

- តាមដាននិងអន្តរាគមន៍ចំពោះការជ្រុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនៅក្នុងរដូវប្រាំងនិងការត្រៀមលក្ខណៈដើម្បីជំរុញការងារបង្កបង្កើនផលដើមរដូវវស្សានេះ

- ការត្រៀមលក្ខណៈដើម្បីសហការរៀបចំព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល ព្រមទាំងចាត់វិធានការទប់ស្កាត់ចំពោះការកំណត់ថ្លៃកសិផលទាបជាងទីផ្សាររបស់ឈ្មួញខិលខូច ដែលធ្វើឲ្យប្រជាជនបាត់ឱកាសក្នុងការលក់កសិផលនានាជាពិសេសស្រូវតាមតម្លៃទីផ្សារពិតប្រាកដ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអត្តុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឲ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងក្លូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា។

### ២.ផ្នែកផលិតកម្មនិងបសុព្យាបាល :

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី-

ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឲ្យបានទូលំទូលាយ

- ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

- ពង្រឹងត្រួតពិនិត្យចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឲ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣.ផ្នែករុក្ខាព្រៃឈើ** :

- បន្តជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក និងការត្រៀមលក្ខណៈដើម្បីរៀបចំពិធីបុណ្យរុក្ខទិវា

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤.ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ជំរុញពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយុទ្ធការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

- ការត្រៀមលក្ខណៈដើម្បីរៀបចំទិវាមច្ឆជាតិនាពេលខាងមុខ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥.ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យមានប្រសិទ្ធភាព និងការបន្តរៀបចំផែនការថវិកាសម្រាប់ឆ្នាំ២០១៦

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឲ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏ត្រូវគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និងយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យនិងចាត់វិធានការសមស្របដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឲ្យបានហ្មត់ចត់

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ និងគោលការណ៍ព្រមទាំងពង្រឹងសមត្ថភាពធនធានមនុស្ស សមត្ថភាពពាក់ព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធទៅតាមអង្គភាពរបស់ខ្លួន ដើម្បីលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជាក្នុងការត្រៀមលក្ខណៈសម្រាប់ការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥ និងនាពេលអនាគត។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**យ៉ុន្ត ត្វិថង**